# អ្នករស់រានមានជីវិតដែលមានបញ្ហាតានតឹងផ្លូវចិត្ត បានគូររូបរបស់ ប៉ុល ពត អមជាមួយសម្រែកឱ្យជួយរបស់អ្នកទោស

ដោយ ឡូរ៉ា ម៉ាកដូណល់

ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩

ប្រែសម្រួលដោយ ទែន សុខស្រីនិត

នាថ្ងៃនេះ អង្គជំនុំជម្រះបានស្តាប់ឮសក្ខីកម្មរបស់ ប៊ូ ម៉េង អាយុ៦៨ឆ្នាំ ដែលជាដើមបណ្តឹងរដ្ឋប្បវេណី និងជាអ្នកទោសទីបីដែលរួចរស់រានមានជីវិតពីគុកទួលស្លែង (មន្ទីរស-២១) ដែលបានមកធ្វើសក្ខីកម្មនៅក្នុងអង្គជំនុំជម្រះរបស់ប្រធានគុក កាំង ហ្គេកអ៊ាវ(ហៅ ឌុច) ។ ដូចគ្នានឹងអ្នកទោសមន្ទីរស-២១ដូចជា វ៉ាន់ ណាត និង ជុំ ម៉ី ដែលបានផ្តល់សក្ខីកម្មកាលពីសប្តាហ៍មុននេះ ជីវិតរបស់ ប៊ូ ម៉េង ត្រូវបានរួចរស់ដោយសារតែគាត់ចេះនូវជំនាញដែល ឌុច ចង់ទាញយកប្រយោជន៍។ ប៊ូ ម៉េង អាចគូររូបសខ្មៅរបស់ ប៉ុល ពត បានយ៉ាងប៉ិនប្រសប់ ។

## រឿងរ៉ាវរបស់ ប៊ូ ម៉េង

ក្រោយពីបក្សកុម្មុយនីស្តកម្ពុជាឡើងកាន់កាប់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥មក ប៊ូ ម៉េង ត្រូវបានរបបខ្មែរក្រហមបញ្ជាឲ្យទៅធ្វើការនៅឯសាលាបច្ចេកទេស ដោយគូររូបម៉ាស៊ីនផ្សេងៗសម្រាប់ឲ្យសិស្សសិក្សា ។ នាពេលមួយក្នុងឆ្នាំ១៩៧៦ ប៊ូ ម៉េង និងប្រពន្ធរបស់គាត់ត្រូវបានបញ្ជូនឲ្យមករស់នៅក្នុងសហករណ៍មួយ ។ នៅទីនោះ គាត់ត្រូវបានបង្ខំឲ្យជីកប្រឡាយ លើកទំនប់ ធ្វើនង្គ័ល និងដាំបន្លែ ហើយចំណែកឯប្រពន្ធរបស់គាត់ត្រូវធ្វើការដកស្ទូងនៅក្នុងស្រែ ។ មានថ្ងៃមួយ ប៊ូ ម៉េង ត្រូវបានខ្មែរក្រហមប្រាប់ថា គាត់ត្រូវផ្លាស់ទៅបង្រៀននៅសាលាវិចិត្រសិល្បៈ ។ ឮដូច្នេះគាត់ និងប្រពន្ធគាត់បានធ្វើដំណើរតាមរថយន្តដោយក្តីសប្បាយរីករាយ ។ ជាអកុសល រថយន្តនោះមិនបាននាំយកគាត់ និងប្រពន្ធគាត់ទៅកាន់សាលាវិចិត្រសិល្បៈទេ ផ្ទុយទៅវិញវាបែរជាទម្លាក់ពួកគាត់នៅមន្ទីរស-២១ ។ មន្ទីរស-២១នេះហើយ ដែលជាកន្លែងដែលគាត់និងប្រពន្ធគាត់ត្រូវបានចាប់ខ្លួន ថតរូប ចងភ្នែក ហើយនាំទៅកាន់បន្ទប់ឃុំឃាំងផ្សេងគ្នា ។ ចាប់តាំងពីពេលនោះមក ប៊ូ ម៉េង មិនដែលបានឃើញមុខរបស់ប្រពន្ធ

គាត់ម្តងទៀតឡើយ ។ គាត់មានតែរូបថតរបស់ប្រពន្ធគាត់ដែលថតនៅអាយុ២៥ឆ្នាំ មានភ្ជាប់លេខសម្គាល់ខ្លួនអ្នកទោសមួយសន្លឹកតែប៉ុណ្ណោះសព្វថ្ងៃនេះ ។

ប៊ូ ម៉េង ត្រូវបានដាក់ច្រវ៉ាក់ជើងនៅក្នុងបន្ទប់ឃុំអ្នកទោសរួមធំមួយជាមួយនឹងអ្នកទោសប្រមាណសែសិបនាក់ផ្សេងទៀតដែលអ្នកទាំងនោះមានសភាព“ដូចមនុស្សនរក” ។ ការរៀបរាប់ពីស្ថានភាព និងការប្រព្រឹត្តមកលើអ្នកទោសរបស់ ប៊ូ ម៉េង មានលក្ខណៈដូចគ្នានឹងសក្ខីកម្មរបស់ជាងគំនូរ វ៉ាន់ ណាតដែរ ។ ប៊ូ ម៉េង បានដេកផ្ទាល់នឹងឥដ្ឋទល់ក្បាលជាមួយនឹងអ្នកទោសផ្សេងទៀត ហើយយ៉ាងហោចណាស់ មានអ្នកទោសម្នាក់បានស្លាប់ដោយសារតែអ្នកយាមគុកជាន់ទន្រ្ទានលើដើមទ្រូងរបស់អ្នកទោសនោះ ។ សាកសពមិនត្រូវបានលើកចេញក្នុងរយៈពេលយ៉ាងយូរ ។ ប៊ូ ម៉េង បាននិយាយពីភាពស្រេកឃ្លានខ្លាំងថា គាត់ចង់ឲ្យសត្វជីងចក់ធ្លាក់ពីលើពិដានដើម្បីឲ្យគាត់បានបំពេញក្រពះរបស់គាត់ ។ ការស្រេកទឹកក៏ជាបញ្ហាដែលកើតមានឡើងរហូត ។ អ្នកទោស“ត្រូវបានលាងសម្អាតខ្លួនដូចសត្វជ្រូក” ដោយបាញ់ទឹកនឹងទុយយ៉ូតាមចន្លោះបង្អួចជារៀងរាល់សប្តាហ៍ ។ អ្នកទោសនាំគ្នាដោះសម្លៀកបំពាក់ដែលពួកគេមានតែមួយគត់គឺ ខោខ្លី នោះចេញដើម្បីផ្លូតទឹកសម្អាតខ្លួន ។ ក្រោយពីអ្នកយាមគុកបានចំអរឡកឡឺចំពោះរូបភាពអាក្រាតរបស់គេរួចមក អ្នកទោសទាំងអស់នាំគ្នាប្រើខោខ្លីនោះជូតទឹកចេញពីឥដ្ឋដើម្បីដេកម្តងទៀត ។ អ្នកទោសកើតបៃ និងរមាស់ពេញខ្លួន ។ គ្មានអ្នកទោសណាម្នាក់អនុញ្ញាតឲ្យនិយាយទេ ។ “វាគឺពិតជាមានសភាពដូចនរកណាស់” ។

អ្នកទោសតែងតែបាត់ខ្លួនជាបន្តបន្ទាប់ ហើយមិនដែលឃើញវិលត្រឡប់មកវិញឡើយរួមទាំងជនជាតិបរទេសមួយចំនួនផងដែរ ។ ប៊ូ ម៉េង បាននិយាយថា អ្នកយាមគុករង់ចាំឲ្យអ្នកទោសមានសភាពទ្រុឌទ្រោមដើម្បីយកមកធ្វើទារុណកម្ម ប្តុក៏ដើម្បីបកស្បែកដូចដែលអ្នកយាមគុកតែងតែនិយាយ ។ ដូច្នេះហើយបានជាអ្នកយាមគុកបានរង់ចាំអស់រយៈពេលប្រាំខែមុននឹងចាប់ផ្តើមសួរចម្លើយ ប៊ូ ម៉េង ។ ក្នុងរយៈពេលជាច្រើនសប្តាហ៍ គាត់ត្រូវទទួលរងការធ្វើទារុណកម្មដោយអ្នកយាមគុកប្រាំនាក់ ។ អ្នកយាមគុកទាំងអស់នេះសួរចម្លើយគាត់ម្នាក់ម្តងរហូតទាល់តែពួកវាអស់កម្លាំង ។ ជាធម្មតា ប៊ូ ម៉េង ត្រូវអ្នកយាមគុកនាំមកផ្ទះមួយនៅខាងក្រៅបរិវេណមន្ទីរស-២១ដើម្បីមកទទួលការវាយនឹងរំពាត់ និងខ្សែតី ។ អ្នកយាមគុកម្នាក់បានទម្លាក់រំពាត់មួយបាច់ក្បែរ ប៊ូ ម៉េង ហើយប្រាប់ឲ្យគាត់រើសយករំពាត់មួយ ។ អ្នកយាមម្នាក់ទៀតបង្ខំឲ្យគាត់រាប់ការវាយខ្នងរបស់គាត់នឹងខ្សែតីឲ្យព្ញៗ ហើយដាក់ទណ្ឌកម្មលើគាត់បន្ថែមទៀតប្រសិនបើគាត់រាប់ខុស ។ ប្រហែលជាការធ្វើឲ្យមានរបួសនៅលើខ្នងមិនទាន់ឈឺណាស់ណា

ហើយមើលទៅ បានជាអ្នកយាមគុកទាំងនោះនាំគ្នាយកដុំគ្រួសមករុះនៅលើមុខរបួសនៅលើខ្នងរបស់ ប៊ូ ម៉េង ។ បន្ទាប់មកទៀតគាត់ត្រូវបានចាក់ទឹកអំបិលនៅលើមុខរបួសដែលដូចជា វិធីសាស្រ្តចុងក្រោយដែលជួយព្យាបាលរបួស ។ ប៊ូ ម៉េង ក៏ត្រូវបានឆក់នឹងខ្សែភ្លើងដោយមានលួសដែលភ្ជាប់ជញ្ជាំងជាមួយម៉ាស៊ីនភ្លើងមកលើភ្លៅខាងលើរបស់គាត់ ។ កម្លាំងភ្លើងជាវ៉ុលបានធ្វើឲ្យគាត់សន្លប់មិនដឹងខ្លួន ហើយក្រោយ មកខ្លួនរបស់គាត់ក៏សើមជោកដោយទឹក ។ មានមេធាវីដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានសួរថាគាត់សន្លប់បាត់បង់ស្មារតីអស់រយៈពេលប៉ុន្មាន ។ ព្ធដូច្នេះ ប៊ូ ម៉េង អស់សំណើចហើយឆ្លើយថា មនុស្សតែសន្លប់ហើយមិនអាចចាប់ពីពេលវេលាបានទេ ។ ដូចដែលធ្វើចំពោះអ្នករស់រានមានជីវិតដទៃទៀតអ្នកសួរចម្លើយបានសួរ ប៊ូ ម៉េង ម្តងហើយម្តងទៀតពីសកម្មភាពចូលរួមជាមួយនឹងពួក សេ.អ៊ី.អា និង កា.ហ្សេ.បេ ។ ក្នុងអំឡុងពេលនោះ ប៊ូ ម៉េង មិនដឹងអ្វីទាំងអស់ពីអង្គភាពអស់នេះ ។ ប៊ូ ម៉េង នៅតែសួរខ្លួនឯងថា ហេតុអ្វីបានជាពួកខ្មែរក្រហមគិតថាគាត់គឺជាគិញសម្ងាត់ បើគាត់បានបំរើបក្សកុម្មុយនិស្តកម្ពុជាដោយស្មោះស្ម័គ្របំផុត ។ ជាចុងក្រោយ ដោយសារតែគាត់មិនព្រមសារភាពអ្នកសួរចម្លើយបានសរសេរចម្លើយសារភាពក្លែងក្លាយហើយឲ្យ ប៊ូ ម៉េង ចុះហត្ថលេខាដោយមិនដឹងពីខ្លឹមសារនៃចម្លើយសារភាពនោះឡើយ ។ បន្ទាប់ពីការធ្វើទារុណកម្មពីរដងក្នុងមួយថ្ងៃជាប្រចាំមក ប៊ូ ម៉េង ត្រូវបាននាំខ្លួនទៅឃុំនៅក្នុងបន្ទប់ឃុំអ្នកទោសដាច់ដោយឡែក ជាជាងឲ្យនៅក្នុងបន្ទប់ឃុំអ្នកទោសរួមដូចមុន ។

មួយរយៈពេលក្រោយពី«ចម្លើយសារភាព»របស់គាត់មក មានអ្នកយាមគុកម្នាក់បានមកសួរថាមាននរណាចេះគូររូបទេ ។ នៅពេលនោះ ប៊ូ ម៉េង បានលើកដៃថា គាត់ចេះគូររូប ។ បន្ទាប់ពីនេះ គាត់ក៏បានទៅជួបផ្ទាល់ជាមួយនឹង ឌុច ដើម្បីធ្វើការសាកល្បងសមត្ថភាពគូរគំនូរជាមួយនឹងខ្មៅដៃនិងក្រដាស់ ។ វ៉ាន់ ណាត មានជំនាញយ៉ាងប៉ិនប្រសប់ក្នុងការគូររូបនឹងទឹកពណ៌ ឯ ប៊ូ ម៉េង វិញ ជំនាញខាងគូររូបគំនូរសខ្មៅ ។ ប៊ូ ម៉េង ទទួលបានរូបថតរបស់ ប៉ុល ពត ដែលដំបូងគាត់មិនស្គាល់ថា ជានរណា ដើម្បីគូរជារូបគំនូរមួយដ៏ធំក្នុងរយៈពេលជាច្រើនខែ នៅក្នុងរោងជាងមួយដែលមានទីតាំងស្ថិតចំកណ្តាលមន្ទីរស-២១ ។ ប៊ូ ម៉េង ក៏បានគូររូបរបស់ ម៉ៅ សេទុង និងរូបសត្វឆ្កែដែលមានក្បាលជាក្បាលរបស់ហូ ជីមិញ ។ ឌុច តែងតែមកតាមដាន និងត្រួតពិនិត្យការគូររូបរបស់ ប៊ូ ម៉េង ជាប្រចាំ ជាពិសេសគឺនៅពេលថ្ងៃដោយមានផ្តល់ការណែនាំដូចជា ចង្អុលបង្ហាញពីរូបករបស់ ប៉ុល ពត ជាដើម ។ មានពេលខ្លះ ឌុច សើចនិងញញឹម ប៉ុន្តែ ឌុច "មិនបានចាត់ទុក ប៊ូ ម៉េង ជាមនុស្សទេ" ។ ឌុច មិនដែលវាយដំ ប៊ូ ម៉េង ដោយផ្ទាល់ទេ ប៉ុន្តែបានគម្រាមគំហែង ប៊ូ ម៉េង ថា ខ្លួនអាចកម្ទេច ប៊ូ ម៉េង ទៅជាអាចម៍ដីបាន ។ មានម្តងនោះ ឌុច បានបង្ខំឲ្យ ប៊ូ ម៉េង វាយគ្នាជាមួយនឹងអ្នកធ្វើការនៅក្នុងរោងជាងជាមួយ

រហូតដល់ ឌុច ស្រែកប្រាប់ឲ្យឈប់ ។ ក្នុងអំឡុងពេលធ្វើការនៅទីនោះ ប៊ូ ម៉េង មានឱកាសសម្រាក នៅក្នុងបន្ទប់ម៉ាស៊ីនភ្លើងជាមួយនឹងអ្នកធ្វើការជាមួយគ្នា ហើយទទួលបានរបបអាហារ«គ្រប់គ្រាន់» ។

ប៊ូ ម៉េង បានឃើញទង្វើរអាក្រក់ដែលបានប្រព្រឹត្តមកលើអ្នកទោសមួយចំនួនដែរ ។ ជនជាតិវៀតណាមម្នាក់ដែលអះអាងថា ខ្លួនអាចសូនរូបក្រមួនបាននោះ ត្រូវ ឌុច ទាត់«ដូចបាល់»បន្ទាប់ពីមិនអាចធ្វើបាននៅក្នុងការសាកល្បងសមត្ថភាព ។ បន្ថែមលើនេះ គាត់បានឃើញអ្នកយាមគុកស្រីទាត់អ្នកទោសស្រីពពោះម្នាក់ដោយហេតុថា អ្នកទោសស្រីនោះដើរយឺតពេក ។ គាត់ក៏បានឃើញបុរសស្គមស្លល់តែស្បែកនិងឆ្អឹងម្នាក់ ត្រូវបានដឹកដាក់ឡានដែលមានចងដៃចងជើងជាប់នឹងឈើ«ដូចសត្វជ្រូក» ។ បើទោះបីជាគាត់មិនបានឃើញទិដ្ឋភាពធ្វើទារុណកម្មដោយផ្ទាល់ក៏ដោយ ក៏ ប៊ូ ម៉េង បានឮសម្លេងយំស្រែកឲ្យជួយដែលហាក់បីដូចជាចេញពី«គ្រប់ទីកន្លែងទាំងអស់» ពីព្រោះថាផ្ទះជាច្រើនដែលប្រើប្រាស់សម្រាប់សួរចម្លើយស្ថិតនៅជុំវិញមន្ទីរស-២១ទាំងអស់ ។ មេធាវីការពារក្តីបានសួរដេញដោល ប៊ូ ម៉េង ពីការអះអាងនេះ ដោយមូលហេតុថា ប៊ូ ម៉េង ក៏បាននិយាយថា អ្នកទោសមិនអនុញ្ញាតឲ្យនិយាយឡើយ ។ ភ្លាមៗនោះ ប៊ូ ម៉េង បានលើកដៃចង្អុលទៅខាងក្រៅ ហើយនិយាយថា «ប្រសិនបើខ្ញុំនិយាយបំផ្លើស ខ្ញុំនឹងត្រូវឡានកិនស្លាប់ជាមិនខាន» ។ មេធាវីការពារក្តីបានព្យាយាមសួរបញ្ជាក់ពីការនិយាយមិនស៊ីគ្នាលើចំណុចមួយចំនួនតូចផ្សេងទៀត ដោយព្យាយាមបញ្ជាក់ពីការចងចាំស្រពិចស្រពិលរបស់ជនរងគ្រោះម្នាក់នេះដែលមានវ័យជរា និងធ្លាប់បានទទួលរងទារុកម្ម ហើយដែលតែងតែនិយាយសុំទោសចំពោះការចងចាំមិនសូវល្អ ។ ជាមួយគ្នានេះ មេធាវីការពារក្តីបានបញ្ជាក់ថា នៅពេលដែល ប៊ូ ម៉េង បំរើការងារនៅសាលាបច្ចេកទេសរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយគូររូបម៉ាស៊ីន ប៊ូ ម៉េង ធ្វើការទៅតាមបញ្ជាដោយភាពភ័យខ្លាច ។ ប្រហែលជាមេធាវីការពារក្តីកំពុងតែបង្កើតភាពដូចគ្នាដ៏តូចមួយនឹង ប៊ូ ម៉េង ដោយថា ឌុច បានធ្វើតាមបញ្ជាឲ្យសម្លាប់អ្នកទោស ១២.០០០នាក់ដោយភាពភ័យខ្លាចដែរ ។

ទោះបីជាសាមសិបឆ្នាំកន្លងផុតទៅក៏ដោយ ក៏ ប៊ូ ម៉េង នៅតែរងទុក្ខវេទនា ។ គាត់ជឿថា ការស្តាប់ឮខ្សោយ ការភ្លេចភ្លាំង ការបាក់ធ្មេញ និងជម្ងឺដេកមិនលក់ដែលគាត់ឆ្លងកាត់នោះគឺបណ្តាលមកពីការធ្វើទារុណកម្ម និងការប្រព្រឹត្តអាក្រក់ផ្សេងៗមកលើរូបគាត់ ។ ប៊ូ ម៉េង និយាយថា គាត់ចាស់ជាងអាយុគាត់ច្រើនណាស់ ហើយកន្លងមកគាត់បានទទួលការព្យាបាលផ្នែកសតិអារម្មណ៍ ។ ប៊ូ ម៉េង មានស្លាក

ស្នាមនៅលើខ្នងរាប់មិនអស់ ។ គាត់ទំនងជាមានអារម្មណ៍គានតឹងរហូតក្នុងអំឡុងពេលធ្វើសក្ខីកម្ម ។ គាត់បាននិយាយថា ៖ «ថ្ងៃនេះខ្ញុំមិនអាចហូបអាហារថ្ងៃត្រង់បានទេ ពីព្រោះខ្ញុំរំជួលចិត្តខ្លាំងពេក» ។

## រឿងដែលខ្វះមួយជំពូក

ភាពដែលអាចកែប្រែបានរបស់ច្បាប់ស៊ីវិលឡូ បានធ្វើឲ្យមានការផ្លាស់ប្តូរដ៏ប្លែកបំផុតសម្រាប់ដំណើរការនីតិវិធីក្នុងថ្ងៃនេះ ។ លោកប្រធាន និល ណុន បានអនុញ្ញាតឲ្យ ប៊ូ ម៉េង សួរ ឌុច ពីទីតាំងដែលប្រពន្ធរបស់គាត់ត្រូវបានសម្លាប់ ។ ក្នុងការស្នើសុំដ៏ក្រៀមក្រំ ប៊ូ ម៉េង បាននិយាយថា គាត់គ្រាន់តែចង់កើបដីដែលកប់សាកសពប្រពន្ធគាត់មកតម្កល់ទុក ដើម្បីឲ្យដួងព្រលឹងរបស់នាងទៅកាន់សុគតិភព ។ ឌុច បានក្រោកឈរឆ្លើយតបដោយក្រៀមក្រំ ។ ឌុច បាននិយាយថា គាត់មានអារម្មណ៍រំជើបរំជួលនឹងសក្ខីកម្មរបស់ ប៊ូ ម៉េង យ៉ាងខ្លាំង ហើយពិតជាចង់ប្រាប់ចម្លើយដល់ ប៊ូ ម៉េង ណាស់ ។ ប៉ុន្តែ ឌុច មិនបានដឹងពីទីតាំងសម្លាប់ប្រពន្ធរបស់ ប៊ូ ម៉េង ទេ ពីព្រោះថាអ្នកអនុវត្តរឿងនេះគឺអ្នកនៅក្រោមបង្គាប់របស់គាត់ ។ ឌុច បានសន្និដ្ឋាន់ថា ប្រពន្ធរបស់ ប៊ូ ម៉េង ត្រូវបានសម្លាប់នៅជើងឯក ។ បន្ទាប់មកទៀត ឌុច បានបង្ហាញ«ការគោរពដ៏ខ្ពស់ខ្ពស់ចំពោះដួងព្រលឹងរបស់ប្រពន្ធ ប៊ូ ម៉េង» ។ ចំណែកឯ ប៊ូ ម៉េង វិញ នៅពេលដែលឃើញ ឌុច អង្គុយចុះ គាត់ស្រាប់តែស្រក់ទឹកភ្នែកតែម្តង ។

## ទិដ្ឋភាពដ៏គួរឲ្យចាប់អារម្មណ៍នៃដំណើរការនីតិវិធី

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ចេញប្រតិកម្មចំពោះអាកប្បកិរិយារបស់លោកប្រធានចៅក្រម និល ណុន ដែលនិយាយទៅកាន់ ជុំ ម៉ី កាលពីម្សិលមិញ ។ នាព្រឹកនេះ មុននឹង ប៊ូ ម៉េង ចាប់ផ្តើមនិយាយ មេធាវី ស៊ីលឃី ស្តូតហ្សិនស្គី បានស្នើសុំឲ្យចៅក្រមអនុញ្ញាតឲ្យសាក្សីសម្រាក ដើម្បីរំងាប់អារម្មណ៍ប្រសិនបើវាជាករណីចាំបាច់ និងសូមអនុញ្ញាតការសម្រាកដូចគ្នានេះដែរក្នុងអំឡុងដំណើរការនីតិវិធី ។ ឧទាហរណ៍ ការអនុញ្ញាតឲ្យសាក្សីពិភាក្សាជាមួយនឹងអង្គការដែលផ្តល់កិច្ចការគាំទ្រចិត្តសាស្រ្ត ។ ស្តូតហ្សិនស្គី ក៏បានស្នើសុំការឈប់សម្រាកដើម្បីរំងាប់អារម្មណ៍នេះ និងសុំមិនរាប់បញ្ចូលពេលវេលាដែលត្រូវចំណាយលើការពិភាក្សាបញ្ហានីតិវិធី ជាមួយនឹងរយៈពេលសួរសំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដោយមូលហេតុថាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមាន«អារម្មណ៍ស្ថិតនៅក្រោមសម្ពាធយ៉ាងខ្លាំង» ។ លោកប្រធានចៅក្រមហាក់បីដូចជាធុញទ្រាន់ បន្ទាប់មក លោកបានពន្យល់ថាចៅក្រមមានការ

ប្រុងប្រយ័ត្នពីការតាមដានពេលវេលាដែលប្រើប្រាស់នៅក្នុងការសួរសំណួរ ហើយពេលវេលាអាចនឹង "ផ្លាស់ប្តូរបានទៅតាមកាលៈទេសៈ" ។ លោកប្រធានចៅក្រមបានបន្តាប់ឲ្យមេធាវីក្រើនរំឭកចៅក្រម ប្រសិនបើសាក្សីត្រូវការជំនួយ ។ លោកប្រធានបាននិយាយថា ចៅក្រមបានធ្វើការកត់សម្គាល់ថា សាក្សីអាចរំងាប់អារម្មណ៍ខ្លួនបាន ។

ជាក់ស្តែង កាលពីម្សិលមិញ ជុំ ម៉ី បានយំជាច្រើនលើក ។ រាល់ពេលដែលយំចៅក្រមតែងតែបន្តាប់ឲ្យគាត់ "រំងាប់អារម្មណ៍ខ្លួនឯង" ។ ដោយឡែក ក្នុងអំឡុងសក្ខីកម្មរបស់ ប៊ូ ម៉េង វិញ លោកប្រធានចៅក្រមបានបន្តាប់ឲ្យសាក្សីព្យាយាមរំងាប់អារម្មណ៍ភ្លាមៗ និងដោយនិយាយពាក្យគួរសម និងខ្ញីផាយស្រួលស្តាប់ជាងមុន ។ លោកប្រធានចៅក្រមតែងតែក្រើនរំឭក ប៊ូ ម៉េង ដែលយំជាច្រើនលើកច្រើនសារនោះថា ប៊ូ ម៉េង បានរង់ចាំឱកាសនេះអស់រយៈពេលជាច្រើនឆ្នាំមកហើយដើម្បីនិយាយ ហើយថ្ងៃនេះគឺជាឱកាសតែមួយគត់សម្រាប់គាត់ដើម្បីរៀបរាប់ពីរឿងរ៉ាវដែលគាត់បានឆ្លងកាត់ ។ បន្ថែមលើនេះ លោកប្រធានបាននិយាយទៀតថា ប្រសិនបើ ប៊ូ ម៉េង មានអារម្មណ៍រំជើបរំជួលខ្លាំងនោះគាត់ប្រាកដជាភ្លេចហេតុការណ៍ដែលបានកើតឡើងជាមិនខាន ។

បន្ទាប់ពីការស្នើសុំលើកដំបូងមក ម្តងនេះ ស្គុតហ្សីនស្គី បានក្រោកឈរឡើងការពារសាក្សីរបស់លោកស្រី ខណៈដែលលោកប្រធានចៅក្រមបន្តាប់ឲ្យ ប៊ូ ម៉េង ដោះអាវចេញដើម្បីបង្ហាញស្លាកស្នាមនៅលើខ្នងរបស់គាត់ជូនចៅក្រម ។ ក្រោយពីការឈប់សម្រាកក្នុងរយៈពេលខ្លី លោកប្រធានបាននិយាយថាអង្គចៅក្រមបានសម្រេចឲ្យមានការថតរូបស្លាកស្នាមនៅលើខ្នងរបស់ ប៊ូ ម៉េង ជំនួសវិញ ។

ជាថ្មីម្តងទៀត មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំពេលវេលាបន្ថែមចំនួនដប់នាទីទៀត ។ ប៉ុន្តែមេធាវីការពារក្តីបាននិយាយថា ប្រសិនបើមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទទួលបានថិរវេលាបន្ថែមនោះមេធាវីការពារក្តីក៏រំពឹកទទួលបានដូចគ្នាដែរ ។ យ៉ាងណាមិញ សំណូមពរនេះត្រូវបានបដិសេធ ។

ការពីថ្ងៃច័ន្ទ ហើយក្នុងថ្ងៃនេះម្តងទៀត លោកប្រធានសហព្រះរាជអាជ្ញាអន្តរជាតិ រ៉ូប៊ឺត ពើទីត មានវត្តមាននៅក្នុងបន្ទប់សវនាការជំនួសមុខឲ្យសហការីរបស់គាត់ម្នាក់ទៀត ។ ប្រហែលជាការធ្វើបែបនេះបង្ហាញថា សាក្សីប៉ុន្មានរូបនេះពិតជាមានសារសំខាន់ ។ មានការសន្និដ្ឋានខ្លះថា រ៉ូប៊ឺត ពើទីត កំពុងតែចំណាយពេលវេលាឲ្យកាន់តែច្រើននៅក្នុងអង្គសវនាការ ដោយសារតែការប្រកាសថ្មីៗនេះដែលថា

លោកនីងលាលែងចេញពីតំណែងនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៩ ។ នៅថ្ងៃច័ន្ទលោកបានធ្វើសេចក្តីសន្និដ្ឋានដ៏ក្បោះក្បាយនិងចោទសួរសំណួរគួរឲ្យចាប់អារម្មណ៍ជាច្រើនដោយប្រុងប្រយ័ត្នបំផុត ។ ដោយឡែកក្នុងថ្ងៃនេះ វ៉ូប៊ឺត ពេទីត គ្រាន់តែបានក្រោកឈរអរគុណសាក្សីចំពោះការធ្វើសក្ខីកម្ម និងទុកឲ្យសហព្រះរាជអាជ្ញាជាតិរបស់គាត់សួរសំណួរ ។ ព្រះរាជអាជ្ញាមិនបានប្រើប្រាស់ពេលវេលាសាមសិបនាទីនោះអស់ទេ ។

ខុសពីសក្ខីកម្មរបស់ ឌុច ដែលភាគច្រើនផ្អែកលើ“សេចក្តីសន្និដ្ឋាន” និង“មតិយោបល់”របស់ខ្លួនបន្ទាប់ពីការពិនិត្យមើលឯកសារសេសសល់នោះ លោកប្រធានបានបញ្ជាក់យ៉ាងច្បាស់នៅថ្ងៃនេះថា ចៅក្រមមិនចាប់អារម្មណ៍នឹងការធ្វើសេចក្តីសន្និដ្ឋាន ឬសន្មត់របស់សាក្សីឡើយ ។ លោកប្រធានបានប្រាប់ ប៊ូ ម៉េង ថា វា“មិនមានលក្ខណៈសមរម្យ”ក្នុងការដែល ប៊ូ ម៉េង ធ្វើសេចក្តីសន្និដ្ឋានឡើយ ។

## សន្និសិទ្ធិកាសែតស្តីពីការខបត្ថម្ភសាក្សី

ប្រធានអង្គភាពឧបត្ថម្ភអ្នកជំនាញ និងសាក្សីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានពន្យល់សង្ខេបដល់អ្នកសារព័ត៌មានពីតួនាទីរបស់ខ្លួននៅក្នុងអង្គជំនុំជម្រះ ។ អង្គភាពឧបត្ថម្ភអ្នកជំនាញនិងសាក្សីផ្តល់នូវសេវាកម្មឧបត្ថម្ភជាច្រើនរួមមាន ការនាំយកសាក្សីមកកាន់អង្គជំនុំជម្រះ ការណែនាំសាក្សីដើម្បីត្រៀមខ្លួនឡើងធ្វើសក្ខីកម្ម និងផ្តល់ជាការឧបត្ថម្ភជាទឹកប្រាក់សម្រាប់ការចំណាយពេលវេលារបស់សាក្សី ។ អង្គភាពឧបត្ថម្ភអ្នកជំនាញ និងសាក្សី ផ្តល់ជូនបន្ថែមនូវសេវាកម្មការពារសាក្សី ដែលសមស្របទៅតាមស្ថានភាពរបស់សាក្សីនីមួយៗ ដោយមូលហេតុថាសាក្សីជាច្រើនមានភាពភ័យខ្លាចចំពោះការសងសឹក និងគម្រាមកំហែងដែលអាចកើតមានឡើង ។ ក្នុងតួនាទីនេះ អង្គភាពឧបត្ថម្ភអ្នកជំនាញនិងសាក្សីធ្វើការពិភាក្សាជាមួយនឹងចៅក្រមដើម្បីស្វែងរកវិធីសាស្ត្រការពារសមរម្យសម្រាប់សាក្សី ។

ដោយមានការកត់សម្គាល់លើអាកប្បកិរិយារបស់លោកប្រធានចៅក្រម និល ណុន សមាជិកអ្នកសារព័ត៌មានមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសេចក្តីណែនាំ ឬបង្គាប់ដែលបានផ្តល់ឲ្យចៅក្រមក្នុងការដោះស្រាយបញ្ហាជាមួយនឹងសាក្សីជនរងគ្រោះដែលមានបញ្ហាតានតឹងផ្លូវចិត្ត ។ ជាក់ស្តែង អង្គភាពឧបត្ថម្ភអ្នកជំនាញ និងសាក្សីផ្តល់សេចក្តីណែនាំ និងព័ត៌មានទៅកាន់ចៅក្រម និងភាគីចូលរួមទាំងអស់ និងជួបប្រជុំពិភាក្សាទាំងអស់គ្នាយ៉ាងទៀងទាត់ ។ បើទោះបីជាការ“តាមដាន និងរិះគន់ចៅក្រម”នេះមិន

មែនជាតួនាទីរបស់អង្គភាពឧបត្ថម្ភអ្នកជំនាញ និងសាក្សីក៏ដោយ ក៏អង្គភាពនេះមានតួនាទីផ្តល់សេចក្តីណែនាំកែលម្អចៅក្រម ។ បើទោះបីជាអ្នកសារព័ត៌មានមិនចង់សួរថា តើអង្គភាពឧបត្ថម្ភអ្នកជំនាញ និងសាក្សីបានផ្តល់មតិកែលម្អដល់លោកប្រធានចៅក្រមបន្ទាប់ពីការសួរសំណួរ ជុំ ម៉ី កាលពីម្សិលមិញក៏ដោយចុះ ក៏ខ្ញុំគិតថាចៅក្រមពិតជាបានប្រជុំពិភាក្សាគ្នាពីរបៀបដោះស្រាយជាមួយនឹងសាក្សីដែលមានអារម្មណ៍រំដើបរំដួល ពីព្រោះយើងឃើញមានវិធីសាស្ត្រដោះស្រាយថ្មីហើយប្លែកមួយនៅថ្ងៃនេះ ។